# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
# ឆ្នាំ២០២២-២០២៤

តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ

តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៣...ស.រ.ណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤

## ១-សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល៖ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដើម្បីឱ្យក្រសួង-ស្ថាប័នសាមីនីមួយៗមានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤។ ក្នុងន័យនេះ សម្រាប់ជំហានបន្ទាប់នៃដំណាក់កាលទី ១, រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជា ផែនការថវិការយៈពេល ០៣ ឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារដែលបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំ) ត្រូវរៀបចំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង

(៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធី, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។

ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា ក៏ជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ជាមួយគ្នានេះ, ក្រសួង-ស្ថាប័ននីមួយៗត្រូវយកចិត្តទុកដាក់លើការកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ដោយធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ។ ដូចនេះ *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់ក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ឬ/និង ថវិកា/គណនេយ្យ ដែលហៅថា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ", អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។*

ក្នុងន័យនេះ ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងៗខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ដូចឆ្នាំកន្លងមកផងដែរ ក្រសួង-ស្ថាប័ននីមួយៗ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អរវាងគ្នាទៅវិញទៅមក ដោយអនុញ្ញាតឱ្យ **ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមីមានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ដើម្បីពិនិត្យ និងកែលម្អកម្មវិធី ដោយផ្តោតការយកចិត្តទុកដាក់លើការពិពណ៌នាកម្មវិធី និងអនុកម្មវិធី និងយកចិត្តទុកដាក់កែលម្អសូចនាករសមិទ្ធកម្ម តាមកម្រិតនីមួយៗនៃរចនាសម្ព័ន្ធកម្មវិធី** ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងគោលដៅបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, **ក្របខ័ណ្ឌថវិការយៈពេលមធ្យម** (ក.ថ.ម) ត្រូវបានដាក់អនុវត្តសាកល្បង ដើម្បីផ្តល់ជាកញ្ចប់ថវិកាក្នុង**កម្រិតពិតានចំណាយ**គោលមួយដល់គ្រប់ក្រសួង-ស្ថាប័ន ដូចមានលម្អិតនៅក្នុង**ផ្នែក**២.៣ សម្រាប់រៀបចំផែនការថវិការយៈពេលមធ្យម ៣ ឆ្នាំរំកិល ទៅតាមរចនាសម្ព័ន្ធកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយដែលនឹងរួមចំណែកសម្រេចអាទិភាព



តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ

គោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្រសួង-ស្ថាប័នត្រូវធ្វើផែនការថវិការយៈពេលមធ្យម ដោយគោរពតាមពិតានចំណាយគោលដែលបានផ្ដល់ជូនសម្រាប់សកម្មភាពការងារ ឬគម្រោងដែលត្រូវបន្តអនុវត្ត ក្នុងក្របខ័ណ្ឌដែលមិនមានការផ្លាស់ប្ដូរខាងអាទិភាពគោលនយោបាយ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលទើបមានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។

ក្នុងន័យនេះ ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ឱ្យកាន់តែមានភាពជាក់ស្ដែង រាជរដ្ឋាភិបាលសូមផ្ដល់ក្របខ័ណ្ឌគោលនយោបាយ ក៏ដូចជាធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ដូចខាងក្រោម៖

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ បានផ្ដល់ទស្សនៈវិស័យរយៈពេលមធ្យមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០២២-២០២៤ ក៏ដូចជាផ្ដល់នូវលំហថវិការួមសម្រាប់ដោះស្រាយនូវតម្រូវការចំណាយរបស់គ្រប់ក្រសួង-ស្ថាប័ន សម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម៖

### ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២១ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនប្រមាណ ៤,០% ពីកំណើនអវិជ្ជមាន ៣,១% នៅក្នុងឆ្នាំ ២០២០ ក្រោមបរិការណ៍នៃការអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ និងការរំពឹងទុកនូវការងើបឡើងវិញ ក្នុងកម្រិតយឺតនៃតម្រូវការសកល, ការបន្ធូរបន្ថយនូវការរឹតបន្តឹងលើការធ្វើដំណើរ និងការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី ព្រមទាំងគិតបញ្ចូលនូវវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលដែលក៏ជាផ្នែកសំខាន់ក្នុងការជំរុញកំណើន។ ឈរលើមូលដ្ឋាននេះ, វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានកំណើនវិជ្ជមានក្នុងកម្រិតទាប ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃអនុវិស័យសំណង់ និងអនុវិស័យកាត់ដេរ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនឹងរក្សាបានកំណើនល្អប្រសើរ។ ទន្ទឹមនេះ, វិស័យសេវាកម្មត្រូវបានរំពឹងថានឹងមានសន្ទុះកំណើនឡើងវិញ ប៉ុន្តែក្នុងអត្រាយឺតជាងនិន្នាការធម្មតា ដោយសារកំណើនទាបនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន, អនុវិស័យអចលនទ្រព្យ និងអនុវិស័យគាំទ្រផ្សេងទៀត។ ចំណែកឯវិស័យកសិកម្មត្រូវបានព្យាករថានឹងបន្តកំណើនប្រហាក់ប្រហែលគ្នាទៅនឹងនិន្នាការធម្មតា ក្រោមការរំពឹងទុកនូវកំណើនល្អឡើងវិញនៃអនុវិស័យដំណាំ និងអនុវិស័យនេសាទ ខណៈអនុវិស័យចិញ្ចឹមសត្វមានកំណើនថមថយ។

សម្រាប់ឆ្នាំ ២០២២ ខាងមុខនេះ, តាមការព្យាករណ៍, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងរង្វង់ ៥,៧% ដោយសារការបន្តងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងសកល ទាំងសកម្មភាពផលិតកម្ម, តម្រូវការ, ការវិនិយោគ និងវំហូរមនុស្ស ដែលនឹងជំរុញដល់ការងើបឡើងវិញនូវអនុវិស័យជំរុញកំណើនសំខាន់ៗ ដូចជា៖ អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន, អនុវិស័យកាត់ដេរ, អនុវិស័យសំណង់ និងអចលនទ្រព្យ និងអនុវិស័យគាំទ្រផ្សេងទៀត។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មដែលអាចសម្រេចបានប្រមាណ ១,១% ដោយសារកំណើនល្អប្រសើរឡើងវិញនៃអនុវិស័យដំណាំ និងការបន្តកំណើនវិជ្ជមាននៃអនុវិស័យនេសាទ និងកំណើនខ្ពស់នៃវិស័យឧស្សាហកម្មក្នុងអត្រាកំណើនប្រមាណ ៨,២% ដោយសារការរំពឹងទុកនូវការងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពផលិតកម្ម, តម្រូវការសកល និងវំហូរទុនវិនិយោគ, ព្រមទាំងការងើបឡើងវិញ នៃវិស័យសេវាកម្មក្នុងអត្រាកំណើន ៥,១% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកភាពប្រសើរឡើងវិញយឺតនៃសកម្មភាពធ្វើដំណើរ និងវំហូរទុនវិនិយោគពីបរទេស ដែលនឹងជួយជំរុញដល់អនុវិស័យអចលនទ្រព្យ, សណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យដែលគាំទ្រដល់សកម្មភាពទេសចរណ៍។

អត្រាអតិផរណា ត្រូវបានព្យាករថានឹងកើនឡើងបន្តិច ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងរង្វង់ ៣,០% ក្នុងឆ្នាំ ២០២២ ដោយសារការកើនឡើងនៃថ្លៃដឹកជញ្ជូន ក្រោមការរំពឹងទុកការងើបឡើងវិញនៃនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីតម្រូវការ និងសកម្មភាពផលិតកម្មសកលមានការកើនឡើងវិញ ស្របពេលដែលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថាស្ថិតក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងកើនឡើងដល់ទំហំ ១៤,៧% នៃ ផសស ក្នុងឆ្នាំ ២០២១ ធៀបនឹង ៦,៦% នៃ ផសស ក្នុងឆ្នាំ ២០២០ ជាមួយនឹងការរំពឹងទុកការកើនឡើងនៃការនាំចូល ដោយសារការងើបឡើងវិញនូវសកម្មភាពប្រើប្រាស់ក្នុងស្រុក និងសកម្មភាពសេដ្ឋកិច្ចជារួម។ ទោះយ៉ាងនេះក្តី, ក្នុងឆ្នាំ ២០២២ ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងរួមតូចបន្តិចមកវិញមកត្រឹមអត្រា ១២,៨% នៃ ផសស ដោយសារការរំពឹងទុកការកើនឡើងនៃការនាំចេញ និងនិន្នាការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ។ ជាមួយ-គ្នានេះ វំហូរទុនវិនិយោគបរទេសត្រូវបានព្យាករថានឹងកើនឡើងវិញដល់ ១២,០% នៃ ផសស ក្នុងឆ្នាំ ២០២១ និង ១២,៣% នៃ ផសស ក្នុងឆ្នាំ ២០២២ ស្របជាមួយការងើបឡើងវិញនូវទំនុកចិត្ត និងសកម្មភាពវិនិយោគសកល។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិសរុប ត្រូវរំពឹងថានឹងបន្តកើនឡើងដល់ ២១ ៦១៧ លានដុល្លារអាមេរិក និង ២២ ១១៨ លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន ១០,៩ ខែ និង ១០,១ ខែ ក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២ រៀងគ្នា។

## ២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២-២០២៤ ដែលរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤"** និង ក្នុងក្របខ័ណ្ឌនៃការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ មានគោលបំណង ដូចតទៅ៖



គេហទំព័រ - ឯកសារម៉ូស្ស៊ីសាធារណៈ

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម;
- ជំរុញការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា;
- បន្តដាក់ចេញក្របខ័ណ្ឌចំណាយអន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាជន ព្រមទាំងធានារក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងដោះស្រាយផលប៉ះពាល់នានាដែលនៅសេសសល់ពីវិបត្តិជំងឺកូវីដ-១៩;
- បន្តអនុវត្តគោលនយោបាយអាទិភាពលើផ្នែកគាំពារសង្គម និងបង្កើនគុណភាពសេវាសុខាភិបាលព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីអាចឆ្លើយតបនឹងគ្រោះអាសន្ន ជាយថាហេតុ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ;
- បន្តតម្រង់ទិសធនធានទៅអភិវឌ្ឍវិស័យអាទិភាព ក្នុងបរិការណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម, វិស័យទេសចរណ៍, វិស័យឌីជីថល និងវិស័យកម្មន្តសាលថ្មីៗ ដើម្បីជំរុញការងើបឡើងនៃកំណើនសេដ្ឋកិច្ច និងពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច;
- បន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យម តាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តជាក់លាក់, ការបង្កភាពងាយស្រួលក្នុងការធ្វើធុរកិច្ច (ease of doing business) ដើម្បីធ្វើឱ្យរស់រវើកឡើងវិញនូវសកម្មភាពអាជីវកម្មក្នុងស្រុក និងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានកម្ចីការប្រាក់ទាប;
- បន្តលើកកម្ពស់វិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, ការអភិវឌ្ឍប្រកបដោយចីរភាព និងការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ ស្របតាមតម្រូវការទីផ្សារ និងប្រក្រតីភាពថ្មី;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង
- បន្តគិតគូរដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករគន្លឹះផ្នែកហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០២២ ដូចខាងក្រោម៖

តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ

- **ចំណូលក្នុងស្រុកសរុប**សម្រាប់ឆ្នាំ ២០២២ ត្រូវគ្រោងសម្រេចឱ្យបាន ២១,៤៦% នៃ ផសស ក្នុងនោះ ចំណូលចរន្តក្នុងទំហំ ២១,២៨% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,១៩% នៃ ផសស។ ចំណូលចរន្តត្រូវបានគ្រោងកើនឡើង ២៧,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៩,២៥% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ២,០៣% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ៨,៣៥% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៩,០៣% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,១៧% នៃ ផសស។
- **ចំណាយសរុបថវិការដ្ឋ**នៅឆ្នាំ ២០២២ នឹងកំណត់ក្នុងរង្វង់ ២៩,២៣% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,២០% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩១% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៨៨% នៃ ផសស។ ចំណាយចរន្តថវិការដ្ឋត្រូវកំណត់ក្នុងកម្រិត ១៦,៨១% នៃ ផសស ដែលក្នុងនោះ៖
    - **ចំណាយបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៤៨,៤៣% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,១៤% នៃ ផសស។
    - **ចំណាយក្រៅបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៥១,៥៧% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,៦៧% នៃ ផសស ដោយផ្តោតលើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ដំណើរការការងារ និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ការការពារ និងទប់ទល់នឹងជំងឺកូវីដ-១៩, ការសម្របខ្លួនទៅនឹងគន្លងថ្មីក្នុងគ្រប់ទិដ្ឋភាព, ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២២ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១២,៤១% នៃ ផសស ក្នុងគោលដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ជាពិសេសជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

**សរុបចំណាយថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ៖** ត្រូវបានគ្រោងប្រមាណ ១,៧៩% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការងារការទូត ពិសេសការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣, ការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការរៀបចំដំណើរការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០២២ និងការត្រៀមរៀបចំការបោះឆ្នោតសកលឆ្នាំ ២០២៣;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ត្រូវបានគ្រោងប្រមាណ ៤,១៨% នៃ ផសស ដោយបន្តផ្តោតលើការគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;

សេចក្តីព្រាង - ឯកសារបង្ហាញសាធារណៈ

- **វិស័យសង្គមកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៧,០៤% នៃ ផសស សំដៅបន្តជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍៖ ការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពការទទួលបានសេវាសុខាភិបាល, ការពង្រឹងប្រព័ន្ធសុខភាពសាធារណៈដែលឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, ផែនការមេសម្រាប់ឆ្លើយតបទៅនឹងជំងឺកូវីដ-១៩, គោលនយោបាយជាតិគាំពារសង្គម ជាពិសេសកម្មវិធីជួយដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ, ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និងគោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន;
- **វិស័យសេដ្ឋកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៨,៥៩% នៃ ផសស ដោយផ្តោតលើការជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍៖ ការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមឆ្នាំ ២០២១-២០២៦, ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីក ២០២១-២០៣០, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ និងការបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា។ លើសពីនេះ គម្រោងចំណាយនៃវិស័យនេះ ក៏ផ្តោតលើជំរុញការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និង ក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥ និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥;
- **ចំណាយផ្សេងៗ៖** ត្រូវបានគ្រោងក្នុងទំហំ ៥,៦១% នៃ ផសស ដើម្បីត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ, និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ កិច្ចការអធិបតេយ្យ និងស្បៀងបម្រុង ជាដើម។

ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០២២ នឹងសម្រេចបានប្រមាណ ៤,៤៦% នៃ ផសស និងឱនភាពថវិកាសរុបនឹងមានទំហំ -៧,៧៦% នៃ ផសស។ ក្នុងក្របខ័ណ្ឌនេះ, ថវិកាឆ្នាំ ២០២២ មានចរិតជាថវិកាវិត្តារកម្ម តាមរយៈការរក្សាសមតុល្យថវិកា និងការផ្តោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយ ទាំងកម្រិតវិភាជ និងប្រតិបត្តិការ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២២ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម៖

### ក. វិធានការផ្នែកចំណូល

#### <u>ក.១-វិធានការផ្នែកចំណូលពន្ធដារ</u>

វិធានការគន្លឹះដាក់លាក់សម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ ក្នុងទិសដៅរក្សាចីរភាពកំណើនចំណូលពន្ធដារ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមក្រោយពេលវិបត្តិជំងឺកូវីដ-១៩ រួមមាន៖



គេហទំព័រ - ឯកសារមន្ត្រីសាធារណៈ

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្ត និងដាក់ចេញនូវវិធានការថ្មីៗចាំបាច់បន្ថែមទៀត ដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ សំដៅទ្រទ្រង់និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ;
- បន្តពិនិត្យ និងកែតម្រូវអត្រាពន្ធកាត់ទុកលើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ គ្រប់ប្រភេទទាំងក្នុង និងក្រៅស្រុក ស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច និងវិបត្តិជំងឺកូវីដ-១៩;
- ពង្រីកវិសាលភាពនៃការប្រមូលចំណូលពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យដោយៈ (១)-ការពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, (២)-ការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន, (៣)-ការពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ, (៤)-ការពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានាតាមច្បាប់ជាធរមាន និង (៥)-បន្តរៀបចំយន្តការសម្រាប់ពង្រឹងការអនុវត្តតារាងឧបសម្ព័ន្ធតម្លៃអចលនទ្រព្យថ្មី សម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ និងពន្ធលើអចលនទ្រព្យ;
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធក្នុងវិស័យកម្មន្តសាលផលិតភេសជ្ជៈ ជាពិសេសស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា;
- បន្តជំរុញការចុះបញ្ជីសហគ្រាស និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ ដើម្បីបង្កើនមូលដ្ឋានអ្នកជាប់ពន្ធ;
- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (business cycle) តាមរយៈការប្រមូល និងវិភាគទិន្នន័យព័ត៌មានអំពីហានិភ័យអនុលោមភាព និងកែសម្រួលឯកសារបច្ចុប្បន្នភាពនៃការវិភាគហានិភ័យទូទៅ;
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម;
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំ និងកាត់បន្ថយការធ្វើសវនកម្មជាន់គ្នា (សវនកម្មពេញលេញ និងសវនកម្មមានកម្រិត) ដើម្បីសម្រួលបន្ទុកដល់អ្នកជាប់ពន្ធ និង
- ធ្វើបច្ចុប្បន្នភាព និងកែប្រែទៅជំនាន់ថ្មីលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា។

<u>ក.២-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ</u>

វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២២ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (អ.គ.រ.) ផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោមៈ

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩,
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,

គេហទំព័រ - ឯកសារផ្លូវការ:

- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ក្នុងករណីចាំបាច់,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់អតិថិជន,
- កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត,
- លើកកម្ពស់ការយល់ដឹងរបស់ធុរជនលើការងារបច្ចេកទេសគយ និងនីតិវិធីនៃការបំពេញបែបបទគយ តាមរយៈការផ្សព្វផ្សាយមគ្គុទ្ទេសក៍ និងវគ្គបណ្តុះបណ្តាលអំពីតម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងការអនុវត្តអត្រាពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងនីតិវិធីគយជាធរមាន,
- បន្តពង្រឹងយន្តការ និងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- បន្តពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបបទល្មើសគយ តាមរយៈការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការវិភាគព័ត៌មាន និងហានិភ័យ, និងការចែករំលែកព័ត៌មានសម្ងាត់ក្នុងកម្រិតទ្វេភាគី តំបន់ និងសកល,
- ពិនិត្យលទ្ធភាពរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគយគ្រប់គ្រងភណ្ឌាគារផលិតកម្មមានដែនកំណត់ដែលធ្វើប្រតិបត្តិការកែច្នៃ ឬចម្រាញ់គេលសិលាធៅ ឬប៊ីទីមខនិជ និង
- ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ទានកម្មបច្ចេកវិទ្យាព័ត៌មានរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធបញ្ចរតែមួយជាតិ, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, និង direct trader input ( DTI )។

### ក.៣-វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

ក្នុងទិសដៅបន្តកំណើនចំណូល និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងប្រភពចំណូលសក្តានុពល បន្ថែមលើវឌ្ឍនភាពសម្រេចបានកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០២២ វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន៖

- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រ ក្នុងន័យបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការកៀរគរចំណូលឱ្យអស់សក្តានុពល;
- ជំរុញការរៀបចំឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ;
- ជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្តថ្មីក្នុងការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច;
- ជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) អនឡាញ នៅតាមក្រសួង-ស្ថាប័ន;

គោលក្រម - ឯកសារមន្ត្រីរាជការ:

- បន្តអភិវឌ្ឍ និងបន្ថែមមុខងារដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ដូចជាការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក (e-payment), ការបន្តធ្វើបច្ចុប្បន្នភាព និងការដាក់បញ្ចូលកិច្ចសន្យាកិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ;
- សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍ ស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈ;
- ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍរមណីយដ្ឋានដែលមានសក្តានុពល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងពង្រឹងការប្រមូលចំណូលឱ្យអស់លទ្ធភាព;
- បន្តដាក់ចេញវិធានការគាំទ្រ ឬអនុគ្រោះ ទៅតាមវិស័យដែលរងផលប៉ះទង្គិចពីជំងឺកូវីដ-១៩;
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល;
- ជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីធនធានរ៉ែ ដោយអនុវត្តយន្តការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក, ជំរុញការអនុវត្តយន្តការអធិការកិច្ចចំពោះក្រុមហ៊ុន ឬអាជីវកម្ម, ពិនិត្យផ្ទាល់ដល់ទីតាំង ឬការដ្ឋានអាជីវកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងទទួលបន្ទុក;
- ពិនិត្យឡើងវិញ និងកែសម្រួលថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច អនុលោមតាមគោលការណ៍ដែលអនុម័តដោយរាជរដ្ឋាភិបាល ដោយតម្រូវឱ្យបង់ថ្លៃឈ្នួលតាមទំហំសម្បទានដីសេដ្ឋកិច្ចដែលទទួលបានជាជាងទំហំដីដែលបានធ្វើការឈូសឆាយ;
- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងអាជ្ញាបណ្ណ និងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ នៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ឱ្យបានពេញលេញ ក្នុងគោលដៅពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល;
- ពិនិត្យ និងរៀបចំយន្តការស្តង់ដារក្នុងការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈផ្អែកលើគោលការណ៍សមធម៌ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល;
- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារ តាមរយៈការជំរុញបន្ថែមនៅពេលប្រតិបត្តិករមកបន្តអាជ្ញាបណ្ណ និងការចុះជំរុញតាមទីតាំងអាជីវកម្មផ្ទាល់។

## ខ. វិធានការផ្នែកចំណាយ

ក្នុងក្របខ័ណ្ឌនៃគោលដៅរក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចឡើងវិញ, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២២ ដូចខាងក្រោម៖

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩;
- តម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ ប្រកបដោយបរិយាបន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាង

ឥតលោភក្រាម - ឯកសារមន្ត្រីសាធារណៈ

ហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, និងការពង្រឹងប្រព័ន្ធគាំពារសង្គម, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធសុខាភិបាល និងវិស័យហិរញ្ញវត្ថុ;

- កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព ដែលទទួលបានគោលការណ៍ឯកភាពពីប្រមុខរាជរដ្ឋាភិបាល តាមសំណើរួមគ្នារបស់ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាមី;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា និងគោលនយោបាយអាទិភាព និងបន្តតម្រង់ទិសការប្រើប្រាស់ធនធានថវិកាជាតិ ដើម្បីជំរុញក្បាលម៉ាស៊ីនកំណើន;
- បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈ;
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី សម្រាប់ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍;
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (រួមបញ្ចូលរដ្ឋបាលរាជធានី-ខេត្ត) និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្ដល់ព័ត៌មានពីសមិទ្ធកម្ម;
- បន្តអនុវត្តយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ដោយជំរុញការខ្ចីឱ្យអស់លទ្ធភាព ប៉ុន្តែសម្រាប់តែវិស័យអាទិភាព ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេសវិស័យបង្កើនផលិតភាពផលិតកម្ម ជំរុញការតភ្ជាប់ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និង
- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្ដើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧។

## ២.៣-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២២-២០២៤

ផ្អែកតាមក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២-២០២៤ ដូចបានកំណត់ខាងលើ ពិតានចំណាយគោលតាមវិស័យត្រូវបានកំណត់ ដូចតទៅៈ

-វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ១,៧៩%, ១,៧៣%, និង ១,៦៦% នៃ ផសស សម្រាប់ឆ្នាំ ២០២២, ២០២៣ និង ២០២៤ រៀងគ្នា,

-វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៤,១៨%, ៤,២២%, និង ៤,២៤% នៃ ផសស សម្រាប់ឆ្នាំ ២០២២, ២០២៣ និង ២០២៤ រៀងគ្នា,



គេហទំព័រ - ឯកសារមន្ត្រីសាធារណៈ

-វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៧,០៤%, ៦,៦៥%, និង ៦,៦៤% នៃ ផសស សម្រាប់ឆ្នាំ ២០២២, ២០២៣ និង ២០២៤ រៀងគ្នា,

-វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ៨,៥៩%, ៨,៧៤%, និង ៨,៤% នៃ ផសស សម្រាប់ឆ្នាំ ២០២២, ២០២៣ និង ២០២៤ រៀងគ្នា,

ក្របខ័ណ្ឌពិតានចំណាយគោលកម្រិតវិស័យនេះ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី។ ឈរលើក្របខ័ណ្ឌនេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) ត្រូវបានកំណត់ជាពិតានចំណាយគោលជូនដល់គ្រប់ក្រសួង-ស្ថាប័ន។ ការអនុវត្តសាកល្បង បានចាប់ផ្តើមពីឆ្នាំ ២០២០ ដោយកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** សម្រាប់គ្រប់ក្រសួង-ស្ថាប័ន។ បន្ទាប់មក **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ** ត្រូវបានអនុវត្តនៅឆ្នាំ ២០២១ សម្រាប់ក្រសួង-ស្ថាប័នចំនួន ៧។ សម្រាប់ឆ្នាំ ២០២២ **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ និងគម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានកំណត់សម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បី ពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា, ការបន្តពង្រឹងវិន័យថវិកា, ការបង្កើនប្រសិទ្ធភាពចំណាយ និងការកែលម្អការវិភាជធនធានសាធារណៈជារួម។

នៅក្នុងការអនុវត្តនេះ, ***ការកំណត់ពិតានចំណាយគោល*** *(Baseline Ceiling)* ត្រូវបានជ្រើសរើសជាអភិក្រមនៃការអនុវត្ត ដើម្បីផ្តល់មូលដ្ឋានច្បាស់លាស់មួយក្នុងផ្តល់កញ្ចប់ថវិកា។ ពិតានចំណាយគោល "គឺជាកញ្ចប់ថវិកាដែលក្រសួង-ស្ថាប័នអាចនឹងទទួលបានសម្រាប់ប្រតិបត្តិការសកម្មភាពការងារ និងកម្មវិធីដែលមានលក្ខណៈជាប្រចាំ ដោយគិតគូរបញ្ចូលនូវកត្តាតម្រូវការ (demand driver) ប៉ុន្តែ ត្រូវបានកាត់ចេញនូវទំហំចំណាយនៃគោលនយោបាយ និង/ឬ សកម្មភាពមិនប្រចាំ **និង/ឬ លទ្ធភាព**ដែលត្រូវបានវាយតម្លៃថាមិនមានប្រសិទ្ធភាព, ដោយឡែក ចំពោះចំណាយសម្រាប់ការកែលម្អផលិតភាពការងារ, ការលើកកម្ពស់ប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយថ្មី នឹងផ្តល់ជូនបន្ថែមទៀតតាមលទ្ធភាពថវិកាជាក់ស្តែងក្នុងឆ្នាំនីមួយៗ ហើយកញ្ចប់ថវិកាទាំងនេះនឹងត្រូវសម្រេចតាមរយៈការពិភាក្សាចរចាថវិកាប្រចាំឆ្នាំ។ អភិក្រមនេះ នឹងត្រូវកែលម្អជាបណ្តើរៗរហូតដល់ឆ្នាំ ២០២៥ ដើម្បីប្រែក្លាយ ក.ថ.ម ឱ្យក្លាយជាក្របខ័ណ្ឌដែលធានាបាននូវធនធានហិរញ្ញវត្ថុ និងថវិកាកាន់តែច្បាស់លាស់សម្រាប់រយៈពេលមធ្យម សម្រាប់គាំទ្រដល់ការសម្រេចបានគោលបំណងគោលនយោបាយ។

តាមគោលការណ៍នេះ **រូបមន្តពិតានចំណាយគោលផ្នែកចំណាយចរន្ត**សម្រាប់ផ្តល់ដល់ក្រសួង-ស្ថាប័ន និងឧបត្ថម្ភធនគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានគិតគូរគណនាដោយផ្អែកជាចម្បងលើថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ដោយបូកបន្ថែមថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីដែលអនុម័តនៅឆ្នាំថវិកា (ឆ្នាំ N) និងត្រូវចាត់ទុកជាចំណាយប្រចាំសម្រាប់ឆ្នាំគ្រោងថវិកា (ឆ្នាំ N+1) ប៉ុន្តែត្រូវកាត់ចេញវិញនូវចំណាយមិនប្រចាំ។ បន្ទាប់ពីនេះ ថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ត្រូវកាត់ចេញនូវថវិកាសម្រាប់អនុវត្តគោលនយោបាយដែល



គេហទំព័រ - ឯកសារអេឡិចត្រូនិចសាធារណៈ

អនុម័តនៅឆ្នាំមុន (ឆ្នាំ N-1) ដែលមិនបានអនុវត្ត។ ដោយឡែក សមាសធាតុផ្សេងៗទៀត ដូចជា អត្រាប្រែប្រួលនៃប្រាក់បៀវត្ស កត្តាអតិផរណា និងកត្តាតម្រូវការ នឹងត្រូវសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើការប្រជុំពិភាក្សាជាមួយនឹងក្រសួង-ស្ថាប័ននីមួយៗ។ សរុបមក **ពិតានចំណាយគោលឆ្នាំ** ២០២២-២០២៤ ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់ក្រសួង-ស្ថាប័ន *ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១* សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤។

## ៣-រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោល-នយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំតាមទម្រង់ដូចខាងក្រោម៖

- ផ្នែកទី១៖ **អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំឡើងដោយចាប់ផ្តើមគូសរំលេចអំពីតួនាទី និងបេសកកម្មរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០២១ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗ ដែលក្រសួង-ស្ថាប័នបានដាក់ចេញ រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- ផ្នែកទី២៖ **អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ*ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤* និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ ទោះបីជារួម គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ គួរពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយ ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពគោល-នយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា ដើម្បីធានាថាគោលនយោបាយនោះ គឺមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងឆ្លើយតបកាន់តែច្បាស់លាស់ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ជាគោលការណ៍ *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពី ២ ឡើយ*។ សូមរៀបចំខ្លឹមសារនៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

• ផ្នែកទី៣៖ **អំពីកម្មវិធី**

*ការរៀបចំកម្មវិធី ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងត្រូវពណ៌នាអំពីគោលបំណងនៃកម្មវិធីនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ។* ដូច្នេះ នៅក្នុងផ្នែកនេះ *គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាត្រូវពិនិត្យឡើងវិញនូវឈ្មោះកម្មវិធី និងអនុកម្មវិធី ព្រមទាំងកែសម្រួលឈ្មោះឱ្យកាន់តែខ្លី និងងាយយល់។ ទន្ទឹមនេះ ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់ការពណ៌នាអំពីកម្មវិធី និងអនុកម្មវិធីឱ្យបានល្អ។ កម្មវិធី និងអនុកម្មវិធីនីមួយៗត្រូវផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ក្នុងដំណើរឈានទៅអនុវត្តថវិកាពព័ត៌មានសមិទ្ធកម្មដែលនឹងចាប់អនុវត្តពីឆ្នាំ ២០២២។* ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា <u>គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើមផងដែរ</u>។ ចំពោះការគាំទ្រផ្នែកបច្ចេកទេសលើរបៀបរៀបចំគម្រោងថវិកាដែលទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាចធ្វើទំនាក់ទំនងផ្ទាល់ជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថានពាក់ព័ន្ធនឹងកិច្ចការនេះ។ ជាគោលការណ៍ ***ក្រសួង-ស្ថាប័ននីមួយៗ អាចមានកម្មវិធីមិនឱ្យលើសពី ៥ ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធី អាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើងដើម្បីឱ្យអគ្គនាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែល ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន ដាក់ចេញនូវ**អនុកម្មវិធី** និង**ចង្កោមសកម្មភាព** សម្រាប់ជាមូលដ្ឋាននៃការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពសំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែក បង្កើតធាតុចេញ (Output) សម្រាប់ចង្កោមសកម្មភាពនោះ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដោយត្រូវគ្របដណ្តប់លើគម្រោង ឬសកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។ ***ទន្ទឹមពេលនៃការរៀបចំគម្រោងថវិកាឆ្នាំ ២០២២ របស់ខ្លួន*** *ក្រសួង-ស្ថាប័នត្រូវរៀបចំបង្កើនចំនួនអង្គភាពថវិកាឱ្យបានជាអតិបរមាដល់អង្គភាពទទួលខុសត្រូវកម្មវិធី និង/ឬ អនុកម្មវិធី ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់កិច្ចសហការលើផ្នែកបច្ចេកទេសលើការពិនិត្យ និងវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យរបស់អង្គភាពដែលអាចនឹងត្រូវបង្កើតជា អង្គភាពថវិកា ឬអង្គភាពថវិកាដែលអាចនឹងប្រែក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលសមត្ថភាព ក្នុងការត្រៀមបង្កើតជាអង្គភាពថវិកា ក្នុងករណីមានការស្នើសុំពីក្រសួង-ស្ថាប័នសាមីនីមួយៗ។*

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាល

ថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬខ្សែបណ្តោយរបស់ក្រសួងនៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញនៅរាជធានី-ខេត្តរៀងខ្លួន អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្តរបស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ ដោយផ្អែកតាមមុខងារ និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

- ផ្នែកទី៤៖ សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬលទ្ធផល

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់វែងលទ្ធផល ឬសមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅសូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែងក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តអនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០២០ ការព្យាករណ៍ស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០២១ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន ដើម្បីជានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីជានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្តកម្មវិធីនីមួយៗ។ រីឯគោលដៅ

គេហទំព័រ - ឯកសារមន្ត្រីសាធារណៈ

សូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណ ឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេលមធ្យម និងវែង (លើសពី ១ ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមានភាពសមស្រប និងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ(សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ *ក្នុងដំណើរឈានទៅអនុវត្តថវិកាសមិទ្ធកម្មនៅឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តោតការយកចិត្តទុកដាក់ជាបណ្តើរៗលើសមិទ្ធកម្ម ដែលតម្រូវឱ្យក្រសួង-ស្ថាប័នយកចិត្តទុកដាក់កែលម្អសូចនាករឱ្យបានល្អប្រសើរ និងមានមូលដ្ឋានទិន្នន័យច្បាស់លាស់។*

- ផ្នែកទី៥៖ **ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល (២០២២-២០២៤)។

ក-ការគ្រោងចំណូល

ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២២-២០២៤ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរណែនាំនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម**តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់-គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់*



គេហទំព័រ - ឯកសារផ្លូវការ

*សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានការកិច្ចប្រមូលចំណូល។*

ខ-ការគ្រោងចំណាយថវិកា

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២២-២០២៤ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូ-សេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយព្រមជាមួយនឹង គោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន (ឬហៅថាចំណាយវិនិយោគ)។ *ដូចគ្នានេះដែរ ពិតានចំណាយគោលនៃចំណាយចរន្តរបស់ក្រសួង-ស្ថាប័ន ត្រូវបានផ្ដល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) ទាំងផ្នែកចំណាយបន្ទុកបុគ្គលិក (ដោយមិនគិតបញ្ចូលនូវរង្វាន់ពីសេវាសាធារណៈ) និងចំណាយមិនមែនបន្ទុកបុគ្គលិកទៅតាមគោលការណ៍ដែលលម្អិតនៅក្នុងផ្នែក ២.៣។*

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២១ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី៖

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២២-២០២៤ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម៖

គេហទំព័រ - ឯកសារផ្លូវការ

• **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ សម្រាប់ឆ្នាំ ២០២២ ត្រូវគ្រោងជាបឋមលើមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០២១ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០២១ ។ ជាមួយនឹងក្តីរំពឹងថាកំណើនសេដ្ឋកិច្ចជាតិនឹងកាន់តែប្រសើរនៅឆ្នាំ២០២២ ក្នុងបរិការណ៍ក្រោយវិបត្តិកូវីដ-១៩, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈនឹងចេញគោលការណ៍លម្អិតសម្រាប់ការដំឡើងបៀវត្សមូលដ្ឋាន និងការដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ ២០២២ នាពេលខាងមុខ។

ដោយឡែក បន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ត្រូវគ្រោងដោយផ្អែកលើមូលដ្ឋាននៃកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០២២ និងឆ្នាំ២០២៣ រៀងគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីត្រូវបានអនុញ្ញាតឱ្យគ្រោងជ្រើសរើសយ៉ាងច្រើន ស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍។ មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ក៏ជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។

• **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០២២ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២២-២០២៤ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកានៃកញ្ចប់ពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ថវិកា និងប្រតិបត្តិការចំណាយ។ ទន្ទឹមនេះ រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។
- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២២ មន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃទំហំពិតានចំណាយគោល។ សម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ត្រូវគ្រោងកើនឡើងក្នុងរង្វង់នៃ**ទំហំពិតានចំណាយគោលរួម ដែលមានកំណើនរួមក្នុងរង្វង់ ៣% ធៀបនឹងទំហំពិតានចំណាយគោលរួមឆ្នាំ ២០២២។ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដែលទទួលបាននូវការប្រគល់មុខងារពីក្រសួងសុខាភិបាល** ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់

ឯកសារចម្លងត្រូវនឹងច្បាប់ដើម - ទេសលេខាធិការ

ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រង ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន សម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) ប៉ុន្តែ **ត្រូវកត់សម្គាល់ថា កញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

• **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១)៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ (ក្រសួងដែលទទួលបានចំណាយវិនិយោគជាទៀងទាត់ ចំនួន ៦ និង ក្រសួងអាទិភាពថ្មី ចំនួន ៣) រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់, ធារាសាស្ត្រ និងវិស័យអប់រំ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២២-២០២៤ ហើយផ្អែកតាមផែនការវិនិយោគសាធារណៈនេះ ដោយត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងមហាផ្ទៃ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និង ក្រសួងសុខាភិបាល នឹងត្រូវបន្តអនុវត្តរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិលសាកល្បង ដើម្បីចាប់ផ្តើមធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ក្រសួងទាំង ៩ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ពិតានចំណាយគោលជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង។ ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេង ទៀតដែលមានតម្រូវការចំណាយវិនិយោគត្រូវសិក្សាឱ្យបានច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំធ្វើអាទិភាវូបនីយកម្មគម្រោង ហើយគោរពស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចតាមលទ្ធភាពថវិកា និងវិធានការផ្អែកចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

• **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍**៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ ដូចចំណាយមូលធនថ្នាក់ជាតិខាងលើដែរ។ ចំពោះក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបាន

តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ

ហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល(២០២២-២០២៤) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

- ផ្នែកទី៦៖ **សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ និងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤។

## ៤-សេចក្តីសន្និដ្ឋាន

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។ ជារួម *គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការតែត្បិត ឬលើកទឹកចិត្តចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ក្រសួង-ស្ថាប័ន។*

សម្រាប់ឆ្នាំ ២០២២ និងបណ្តាឆ្នាំខាងមុខ, ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់កែលម្អផែនការយុទ្ធសាស្ត្រថវិកាឱ្យស្របទៅតាមអាទិភាពគោលនយោបាយ ដែលមាននៅក្នុង*យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤* ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា និងត្រូវគ្រោងចំណាយស្របទៅតាមពិតានគោលរយៈពេល ៣ ឆ្នាំ និងធនធានដទៃទៀតដែលរំពឹងថានឹងទទួលបានពីដៃគូអភិវឌ្ឍន៍ ឬប្រភពដទៃផ្សេងទៀត ប្រកបដោយភាពជាក់ស្តែងនិយម។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២២-២០២៤ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២១* ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ ដើម្បីសម្រួលដល់ដំណើរការពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) តាមពេលវេលាដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។



គេហទំព័រ - ឯកសារមន្ត្រីសាធារណៈ

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណី ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ **ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២១។**

ថ្ងៃ សុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ: